## មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ញ៉ឹក អ៊ិន ភេទប្រុស អាយុ៥៤ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ឃ្វាលគោ**

**ស្រុកកំណើតនៅភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរណ៍ ខេត្តកំពង់ធំ**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:០២:៣២**

**២៥ទំព័រ**

ដានីៈ អីចឹងលោកពូដបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ?

អ៊ិនៈ ញ៉ឹក អ៊ូន ។

ដានីៈ ឈ្មោះ ញ៉ឹក អ៊ិន?

អ៊ិនៈ បាទ!

ដានីៈ «អ» ដាក់ «ៈ» និង«ន»?

អ៊ិនៈ បាទ!

ដានីៈ លោកពូជនជាតិខ្មែរ?

អ៊ិនៈ ជនជាតិខ្មែរ ។

ដានីៈ ហើយអាយុប៉ុន្មានហើយលោកពូ?

អ៊ិនៈ អាយុ៥៤ហើយ ។

ដានីៈ កើតឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានទៅ?

អ៊ិនៈ ១៩៥៨ ។

ដានីៈ គ្រួសារឈ្មោះអីដែលលោកពូ?

អ៊ិនៈ ឈ្មោះ ឯម អៀង ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

អ៊ិនៈ អាយុ៥១ឬ៥២ កើត១៩៦០ ។

ដានីៈ ៥២ ប្អូនលោកពូ២ឆ្នាំ ។ លោកពូកំណើតកើតជានៅភូមិអីដែរ?

អ៊ិនៈ ភូមិទំនប់ ។

ដានីៈ ឃុំ?

អ៊ិនៈ ឃុំស្រើង ។

ដានីៈ ស្រុក?

អ៊ិនៈ ស្រុកប្រាសាទសំបូរ ។

ដានីៈ ខេត្តកំពង់ធំ ។

អ៊ិនៈ ខេត្តកំពង់ធំ ។

ដានីៈ ហើយលោកពូសព្វថ្ងៃរស់នៅក្នុងភូមិអីដែរ? ភូមិនេះ?

អ៊ិនៈ ភូមិទួលប្រាសាទ ។

ដានីៈ ឃុំ?

អ៊ិនៈ ទំនប់ដាច់ ។

ដានីៈ ស្រុក?

អ៊ិនៈ ស្រុកត្រពាំងប្រាសាទ ។

ដានីៈ ខេត្ត?

អ៊ិនៈ ខេត្តឧត្តរមានជ័យ ។

ដានីៈ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

អ៊ិនៈ អត់មានកូនទេ ។

ដានីៈ លោកពូអត់មានកូនទេ?

អ៊ិនៈ អត់សោះ អត់មាន មានតែពីរនាក់យាយតា ។

ដានីៈ នេះសុទ្ធតែក្មួយៗទេ?

អ៊ិនៈ សុទ្ធតែក្មួយ ។

ដានីៈ ពីរនាក់យាយតា?

អ៊ិនៈ ពីរនាក់យាយតា ។

ដានីៈ លោកពូសព្វថ្ងៃក្រៅពីយើងធ្វើមេភូមិ លោកពូធ្វើអីខ្លះទៀត?

អ៊ិនៈ មានធ្វើអី ប្រជាជនធម្មតា ។

ដានីៈ លោកពូធ្វើជាមេភូមិតាំងពីឆ្នាំណាមក?

អ៊ិនៈ ខ្ញុំធ្វើមេភូមិពីយើងសមាហរណកម្មមក ៩៨ ។

ដានីៈ ធ្វើមករហូត?

អ៊ិនៈ ៩៨-៩៩ ។ ៩៩ទេ ។

ដានីៈ លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

អ៊ិនៈ បងប្អូន៥នាក់តែស្លាប់អស់ហើយនៅសល់តែ៣ ។

ដានី៖ សល់តែ៣នាក់?

អ៊ីន៖ បាទ!

ដានី៖ ៥នាក់ហ្នឹង ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

អ៊ីន៖ ៥នាក់ ស្រី៣ ។

ដានី៖ ប្រុស២?

អ៊ីន៖ បាទ!

ដានី៖ ស្លាប់អស់២នាក់ ស្លាប់ស្រី ឬប្រុស?

អ៊ីន៖ ស្លាប់ស្រី១ ប្រុស១ ។

ដានី៖ គាត់ស្លាប់ដោយសារមូលហេតុអី?

អ៊ីន៖ ឈឺ ។

ដានី៖ ទើបស្លាប់ក្រោយឆ្នាំ៧៩នេះ ឬក៏ស្លាប់យូរហើយ?

អ៊ីន៖ ស្លាប់បងស្រី ស្លាប់ពីឆ្នាំចិតប៉ុន្មានទេ តាំងពីយើងអាមេរិកទម្លាក់គ្រាប់បែក ។

ដានី៖ តាំងពីជំនាន់អាមេរិកទម្លាក់ជាប់បែកឆ្នាំចិតជាង យើងមិនទាន់បាយរួមផង?

អ៊ីន៖ បាទ!

ដានី៖ ហើយប្អូនប្រុស?

អ៊ីន៖ ដែលស្លាប់នោះ?

ដានី៖ បាទ!

អ៊ីន៖ បងគេបង្អស់ ។

ដានី៖ ហ្នឹងស្រី?

អ៊ីន៖ ស្រី ។

ដានី៖ ចុះប្រុស?

អ៊ីន៖ បន្ទាប់មកបងប្រុស ។

ដានី៖ បងប្រុសគាត់ស្លាប់យ៉ាងម៉េចដែរ?

អ៊ីន៖ ស្លាប់ឈឺ ស្លាប់ដោយជំងឺ បើយើងតាមអរូបិយ៍ជឿគេថាគេធ្វើ បើយើងអត់ជឿងគ្រុនឈឺ ។

ដានី៖ តាំងពីអង្គាល់ដែលបងប្រុស?

អ៊ីន៖ ស្លាប់ឆ្នាំ១៩៨៥ ។

ដានី៖ លោកពូកូនទីប៉ុន្មានដែរ?

អ៊ីន៖ ខ្ញុំកូនទី៣ ។

ដានី: ឪពុកពូគាត់ឈ្មោះអីដែរ?

អ៊ិនៈ ត្រកូលគាត់អត់ដឹងតែ តែឈ្មោះទួន ។

ដានី: ត្រកូលអត់ចាំ?

អ៊ិនៈ អត់ចាំ ។

ដានី: ចុះលោកពូដាក់ ញ៉ឹក អ៊ិន?

អ៊ិនៈ ត្រកូលនេះដាក់ខាងម៉ែ ។

ដានី: ត្រកូលខាងម្តាយ?

អ៊ិនៈ ញ៉ឹក ហៀន អីចឹងខ្ញុំដាក់រហូត ។

ដានី: ម្តាយលោកពូឈ្មោះ ញ៉ឹក អៀន?

អ៊ិនៈ ញ៉ឹក ហៀន ។

ដានី: ម៉េចបានលោកពូដាក់ត្រកូលខាងម្តាយ?

អ៊ិនៈ ខ្ញុំអត់ដឹងនៅតូច ។

ដានី: ម្តាយញ៉ឹក ហៀន?

អ៊ិនៈ បាទ! អីចឹងយើងយកត្រកូលហ្នឹងយកមកដាក់រហូត ។

ដានី: ឪពុកអត់ដឹងថាគាត់ដាក់អីទេ?

អ៊ិនៈ បាទ!

ដានី: ជីតាលោកពូឈ្មោះអីដែរ?

អ៊ិនៈ ប៉ិញ ដល់អីចឹងមានដាក់ប៉ិញ ណាទៅជា ញ៉ឹក ខ្ញុំដាក់អីចឹងរហូតទៅ ។

ដានី: អីចឹងឪពុកលោកពូសព្វថ្ងៃគាត់នៅដែរ?

អ៊ិនៈ ស្លាប់ហើយ ។

ដានី: ស្លាប់តាំងពីអង្កាល់ទៅ?

អ៊ិនៈ ស្លាប់មើល ២០០៧ស្លាប់ ។

ដានី: ស្លាប់ឆ្នាំ២០០៧?

អ៊ិនៈ បាទ!

ដានី: ចុះម្តាយលោកពូ?

អ៊ិនៈ ម្តាយដើរអត់រួចទេសព្វថ្ងៃ គាត់នៅញ័រៗនៅកន្ទេល បត់ដៃបត់ជើងយើងលើក ប្អូនខ្ញុំនៅថែរហូត លើកចុះលើកឡើង ដើរអត់រួច មើលអត់ឃើញទេ ។

ដានី: គាត់អាយុប៉ុន្មានហើយ?

អ៊ិនៈ អាយុ៨៤ហើយ ។

ដានីៈ គាត់ជរាហើយ?

អ៊ិនៈ ជរា មុនថាគាត់ផុតហើយ ខ្ញុំទៅមិនចង់ទាន់ ដល់ធ្វើបុណ្យសង្ឃទានទៅដូចថាគាត់ដឹងខ្លួនមកវិញ បាននៅដល់សព្វថ្ងៃ ។

ដានីៈ តែគាត់នៅចាំកូនចៅ ស្មារតីគាត់នៅល្អដែរ?

អ៊ិនៈ អត់ទេ បើយើងទៅអង្គុយចេះ គាត់សួរ ពីណា? ហើយខ្ញុំប្រាប់ថាកូនឈ្មោះនេះៗ នៅនេះៗទៅ ហើយគាត់កូនអើយ យំហើយ ។

ដានីៈ លោកពូកាលពីក្មេងៗបានរៀនសូត្រដល់ណាដែរ?

អ៊ិនៈ ខ្ញុំពីក្មេងអត់បានរៀនសូត្រអីទេ រៀនសាលាដល់រៀនបាន១ខែកើតរដ្ឋប្រហារ ជំនាន់ឆ្នាំ៧០ ឈប់រៀនទៅនៅវត្ត បានប៉ុន្មានខែគេផ្សឹកលោកអស់ទៅ ក៏នៅផ្ទះ គ្មានបានរៀនអីនឹងគេទេ

ដានីៈ អីចឹងលោកពូរៀនបានមួយខែរដ្ឋប្រហារហ្នឹងក៏ឈប់ ទៅនៅវត្ត នៅវត្តណាទៅ?

អ៊ិនៈ នៅវត្តដាំបីង ។

ដានីៈ វត្តដាំបីងក្នុងឃុំ?

អ៊ិនៈ ឃុំស្រើង ស្រុកខេត្តដូចគ្នា ។

ដានីៈ តែអត់បានបួសទេ?

អ៊ិនៈ អត់បានទេ បើគេផ្សឹកលោកហើយមានបានបួសអី ។

ដានីៈ ដល់អីចឹងត្រឡប់មកនៅផ្ទះ?

អ៊ិនៈ នៅផ្ទះទៅ ។

ដានីៈ មកនៅផ្ទះធ្វើអីវិញទៅ?

អ៊ិនៈ ធ្វើស្រែ ធ្វើចំការ ។

ដានីៈ ធ្វើស្រែ ធ្វើចំការជាមួយឪពុកម្តាយ?

អ៊ិនៈ ជាមួយឪពុកម្តាយ បងប្អូន ។

ដានីៈ ធ្វើរហូតដល់ពេលណាទៅ?

អ៊ិនៈ ធ្វើរហូតមកដល់ខ្ញុំបានប្រពន្ធ ។

ដានីៈ លោកពូធ្វើស្រែនៅផ្ទះរហូត?

អ៊ិនៈ នៅផ្ទះរហូត ដល់៨៣ ប៉ែតប៉ុន្មានទេរៀបការនេះ ។

ដានីៈ លោកពូដល់ពេលឆ្នាំ៧៥ លោកពូនៅផ្ទះដែរ?

អ៊ិនៈ នៅផ្ទះ នៅជាមួយបន្ទុកឪពុកម្តាយ ម៉ែឪទាំងអស់ ។

ដានី: ពីព្រោះយើងរដ្ឋប្រហារឆ្នាំ៧០ យើងចាប់ផ្តើមមានសង្គ្រាមស៊ីវិល ខាងខ្មែរក្រហម ហើយខាងលន់ នល់ យើងចាប់ផ្តើមវៃគ្នា តែកាលហ្នឹងអត់ទាន់មានបាយរួមអីទេ?

អ៊ិន: អត់ទេ ៗ

ដានី: ដល់ពេលណាបានបាយរួម?

អ៊ិន: អត់ចាំឆ្នាំទេ មិនសូវចាប់អារម្មណ៍រឿងថ្ងៃខែឆ្នាំ គេបង្កើតបាយរួម អត់ចាំ មិនយកចិត្តទុកដាក់ ៗ

ដានី: តែពីឆ្នាំ៧៥ទៅយើងចាប់ខាងកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមយើងវៃឈ្នះលន់ នល់ យើងចាប់ផ្តើម ពេលហ្នឹងនៅតាមសហករណ៍?

អ៊ិន: នៅតាមសហករណ៍ បាយរួម តែមិនដឹងជាឆ្នាំណា អត់ចាំឆ្នាំ ដឹងតែបាយរួម យើងនៅជាមួយឪពុកម្តាយហ្នឹងគេឲ្យយើង ៗ

ដានី: យ៉ាងម៉េចទៅ គេឲ្យធ្វើអីខ្លះ?

អ៊ិន: ក្មេងៗគេឲ្យយើងជញ្ជូនអាចម៍គោដាក់ស្រែ ក្មេងៗតូច ៗ

ដានី: ក្មេងៗតូចជញ្ជូនអាចម៍គោ?

អ៊ិន: ដាក់ស្រែ ៗ

ដានី: នៅក្នុងភូមិលោកពូ?

អ៊ិន: បាទ?

ដានី: និយាយកាលហ្នឹងជញ្ជូនអាចម៍គោនៅក្នុងភូមិ ឬនៅក្នុងកងចល័ត ឬស្អីដែរ?

អ៊ិន: អត់ចូលចល័តទេ នៅក្នុងភូមិក្មេងៗ ៗ

ដានី: ដល់ឆ្នាំណាទៅបានលោកពូចូលកងចល័ត? បានប៉ុន្មាន?

អ៊ិន: ខ្ញុំអត់បានចូលកងចល័តនឹងគេទេ ខ្ញុំនៅជាមួយឪពុកម្តាយរហូត ទទួលយួន ដល់ពេលយួនវៃគេរត់ ដល់គេរត់គេប្រមែលប្រមូលទ្រព្យយើងពីដើម ក្របី គោ យើងនាំគ្នាចាប់គោ ចាប់ក្របីយើងមកវិញ ៗ

ដានី: អីចឹងលោកពូមានប្រសាសន៍ថាយួនចូលហ្នឹង យួនចូលឆ្នាំ៧៩ ឬយួនចូលមុនហ្នឹង? ពេលដែលយួនចូល៧៩យើងរត់ ឬយ៉ាងម៉េច?

អ៊ិន: ដែលយួនចូល៧៩ហើយយួនចូល ៧៩-៨០នេះ ៗ

ដានី: យួនចូលគេចំណាំតែ ថ្ងៃ៧ មករា ឆ្នាំ៧៩ ៗ ហ្នឹងបានន័យថាយួនចូលពេលហ្នឹង?

អ៊ិន: បាទ!

ដានី: ឬក៏មានអីមុនហ្នឹង?

អ៊ិនៈ	អត់សួរចាំដែរ គេរត់ៗនឹងគេ ។

ដានីៈ	កាលហ្នឹងលោកពូកើតឆ្នាំ៥៨ បើយើងគិតមកឆ្នាំ៧៥ អាយុច្រើនដែរ?

អ៊ិនៈ	អាយុច្រើន អាយុម្ភៃជាង ។

ដានីៈ	តែម្ភៃជាងយើងនៅជាមួយឪពុកម្ដាយម៉េចកើត?

អ៊ិនៈ	នៅជាមួយឪពុកម្ដាយ ។

ដានីៈ	គេម៉េចឲ្យនៅ?

អ៊ិនៈ	គេអត់ឲ្យនៅទេ តែខ្ញុំនៅឃ្វាលក្របីរួមគេ ធ្វើស្រែជាមួយអ៊ំ យាយ តាចាស់ៗ ។

ដានីៈ	ធ្វើស្រែគេមានផ្ទាស់ទៅណាខ្លះដែរ?

អ៊ិនៈ	អត់មានផ្លាស់ទេ នៅនឹងភូមិហ្នឹង ភ្ជួរចេះតែភ្ជួរទៅ គេឲ្យមើលក្របីផង គេឲ្យភ្ជួរស្រែផង ជាមួយតាៗ ។

ដានីៈ	នៅរហូតទាល់តែនេះ?

អ៊ិនៈ	នៅរហូតដល់ឆ្នាំ៨៣ ម៉ែឪរៀបចំគ្រួសារឲ្យ ដល់រៀបបាន១ឆ្នាំ ធម្មតាយើងចង់មានចង់បាន មានប្រពន្ធ កូនហើយ ខ្ញុំដុតពន្ធុតដល់ភ្លើងឆេះយើងត្រកងឈើមកទម្លាក់ អាជើងអង្កត់វាមុតដៃដល់ខ្ញុំសព្វថ្ងៃ ។ កាលនោះជីវភាពយើងក្រីក្រ ហូបបបរ ដករំដេងដោះដូរអង្ករដល់ខ្ញុំធ្វើអត់បាន ប្រពន្ធខឹង ដល់ប្រពន្ធខឹងខ្ញុំនៅដេកផ្ទះ ទៅធ្វើអីបើដៃហើមឡើងលិប ។

ដានីៈ	ពីណាប្រពន្ធខឹង?

អ៊ិនៈ	ប្រពន្ធខ្ញុំ ដល់អីចឹងខ្ញុំខឹង ឃើញពួកខ្មែរក្រហមគេហ្នឹង គេចុះទៅការដល់ហ្នឹង៨៤ ខ្ញុំខឹងឯងនៅទៅអញអត់នៅទេ អញនៅធ្វើការមិនកើត អញទៅចូលព្រៃ ក៏ទៅចូលព្រៃនឹងគេទៅ ចោលម៉ែ ចោលឪ ចោលប្រពន្ធ ទៅចូលព្រៃ ។ ពីដើមខ្លាចដែរទាក់ទាមៗ ដល់ពួកព្រៃគេឃើញគេប៉ោយដៃ សួរថាមកធ្វើអី? ខ្ញុំចូលព្រៃដែរ គេឲ្យចូលទៅ ។

ដានីៈ	ទៅនៅជាមួយក្រុមណា?

អ៊ិនៈ	ទៅនៅជាមួយក្រុមតាពីន ។

ដានីៈ	ឆ្នាំ៨៤ហើយ?

អ៊ិនៈ	ឆ្នាំ៨៤ខ្ញុំចេញ ការបានមួយឆ្នាំហើយ ។

ដានីៈ	ការបានមួយឆ្នាំ ការឆ្នាំ៨៣អីចឹង?

អ៊ិនៈ	បាទ! ការឆ្នាំ៨៣ ៨៤ខ្ញុំ ។

ដានីៈ	អីចឹងមីងគាត់អ្នកនៅភូមិជាមួយគ្នាដែរ?

អ៊ិនៈ	ភូមិជាមួយ និយាយទៅវាដូចបងប្អូនជីដូនមួយ ចាស់ទុំគាត់ដឹង ។

ដានីៈ ដល់ពេលលោកពូទីងអីចឹងឆ្នាំ៨៤ចេញទៅចូលព្រៃ ភូមិលោកពូនៅជិតព្រៃដែរ?

អ៊ីនៈ ជាប់ព្រៃ ធម្មតាយើងអ្នកស្រុកលើ ព្រៃជាប់រហូត ។

ដានីៈ ខាងហ្នឹងផ្លូវទៅខាងព្រះវិហារ?

អ៊ីនៈ ផ្លូវទៅព្រះវិហារក៏ត្រូវ មកពីខាងកំពង់ធំក៏ចូលត្រូវ ព្រោះខ្ញុំនៅភូមិទំនប់ស្រើង ព្រៃលើ មិនមែនអ្នកស្រែនឹងគេណា អ្នកចំការ គ្មានអ្នកណាធ្វើស្រែទេ ។

ដានីៈ ខាងស្រុកលោកពូអត់មានធ្វើស្រែទេ?

អ៊ីនៈ បានស្រែចែកធ្វើ បានចំណែកសេសសល់ពីមួយជំនាន់៣ឆ្នាំ ប៉ុន្មានខែ គាស់កាយក៏នាំគ្នាចែកគ្នាធ្វើ ចំដីយើងៗបានកន្ទះហាត់ មួយហាត់ក៏ធ្វើទៅ ។

ដានីៈ ដល់ពេលលោកពូចូលទៅក្នុងព្រៃជាមួយខាងខ្មែរក្រហម ចូលជាមួយក្រុមឈ្មោះតាពីន?

អ៊ីនៈ បាទ!

ដានីៈ តាពីន ហ្នឹងគាត់ធ្វើប្រធានអី?

អ៊ីនៈ ប្រធានវរសេនាធំមិនដឹង វរសេនាតូចទេកាលហ្នឹង ។

ដានីៈ វរសេនាធំ ឬវរសេនាតូចតាពីន?

អ៊ីនៈ វរសេនាធំ ។

ដានីៈ កងពលលេខប៉ុន្មានកាលហ្នឹង?

អ៊ីនៈ កងពលនៅ៨០២ ។

ដានីៈ ពីណាគេប្រធានកងពលកាលហ្នឹង?

អ៊ីនៈ ភ្លេចឈ្មោះគាត់ទៅ បាត់មុខយូរណាស់ហើយតាហ្នឹង ឈ្មោះតាអីទេ ។

ដានីៈ តាឆន?

អ៊ីនៈ តាហ្នឹង តាឆន ៨០២ ។

ដានីៈ គាត់បងប្អូនជាមួយតាសុន សេន?

អ៊ីនៈ ខ្ញុំអត់សួរដឹងទេ យើងអ្នកចេះមិនងាយទេ មិនងាយដឹង ។

ដានីៈ លោកពូចូលដំបូងធ្វើអីខ្លះទៅ?

អ៊ីនៈ ធ្វើទាហានដើរតាមគេ គេទៅណាទៅតាមគេ ។

ដានីៈ កាលហ្នឹង៨៤ពេលដែលយើងចូលហើយ យើងទៅធ្វើប្រតិបត្តិការនៅណាខ្លះទៅ?

អ៊ីនៈ គេអត់ទាន់ឲ្យដើរទេយើងថ្មី ឲ្យយើងនៅដាំបាយឲ្យគេហូប បានមួយឆ្នាំបានគេឲ្យយើងដើរ ដើរនៅតាមគាត់រហូត ដើរធ្វើការនៅកំពង់ធំ ។

ដានីៈ អីចឹងកងពល៨០២ធ្វើការនៅកំពង់ធំទេ?

អ៊ិនៈ បាទ!

ដានីៈ ចាំមើល៨៤ពេលចូលដំបូងលោកពូនៅខាងកំពង់ធំ ឬយើងឡើងមកខាងដងរែក?

អ៊ិនៈ នៅកំពង់ធំ ចូលទៅនៅហ្នឹង នៅក្នុងព្រៃដាំបាយឲ្យគេស៊ីហ្នឹង ។

ដានីៈ កាលហ្នឹងប្រពន្ធអី?

អ៊ិនៈ ប្រពន្ធនៅផ្ទះ ទៅតែខ្ញុំទេ ។

ដានីៈ ដែលមកលេងគាត់អត់ពេលចូល?

អ៊ិនៈ អត់ដែលបានមកលេងទេ ដល់ចូលនៅហ្នឹងបានប្រហែលមួយឆ្នាំបានគេឡើងភ្នំ ។

ដានីៈ ឆ្នាំ៨៥ហ្នឹង?

អ៊ិនៈ ៨៥ហ្នឹងគេឡើង ។

ដានីៈ ឡើងភ្នំលោកពូឡើងមកដែរ?

អ៊ិនៈ ឡើង ។

ដានីៈ ឡើងភ្នំឡើងមកនៅណា?

អ៊ិនៈ ឡើង នៅក-៧ កន្លែងក-៧ គេហៅក-៧ៗ ។

ដានីៈ ឡើងភ្នំនៅ ក-៧ហ្នឹងនៅកន្លែងណាទៅ?

អ៊ិនៈ អត់ដឹងត្រង់ណា ត្រង់ណី ដល់ពេលចុះមកអត់ដឹង បើគេឡើងតាមច្រកអន្លង់វែងហ្នឹងដើរកាត់ដីថៃ មិនដឹងកុងកេរទៅប្រឡោះណាវិញដល់យើងមកនៅ ចុះមកវិញចុះតាមហ្នឹងដែរ គេឲ្យមកនៅដីខ្មែរ ចុះតាមហ្នឹងឯង ។

ដានីៈ ឆ្នាំ៨៥ពូឡើងភ្នំដងរែក មកនៅកន្លែងក-៧ កាលហ្នឹងមកជាមួយដែរ?

អ៊ិនៈ អត់ទេ តែឯងទេ ។

ដានីៈ តែឯងទៀត?

អ៊ិនៈ តែឯង ។

ដានីៈ ដល់ពេលឡើងមកក-៧ហ្នឹងឡើងបានយូរទេ?

អ៊ិនៈ ឡើងនៅបាន៣ខែ ៣ខែចុះមកវិញ ។

ដានីៈ ចុះមកនៅណាវិញ?

អ៊ិនៈ ចុះមកនៅកំពង់ធំ ។

ដានីៈ ចុះមកនៅម្តុំណា?

អ៊ិនៈ នៅមួយជួយការភូមិខ្ញុំហ្នឹង ហៅព្រៃឡង់ វាលស្មោង នៅក្រឡឹងក្បែរៗភូមិ ។

ដានីៈ ពេលដែលមកហ្នឹង មកគ្នាច្រើនទេ?

អ៊ិនៈ កំលាំងគេច្រើន មកដល់បែកតាមមុខសញ្ញាគេធ្វើការ គេបែកអស់ទៅ ខ្លះគេឆ្លងទៅណាអស់ទៅ ។

ដានីៈ នៅវរសេនាធំរបស់តាពីន ហ្នឹងដដែលឬផ្លាស់ប្តូរ?

អ៊ិនៈ នៅជាប់រហូតដល់យើងសមាហរណកម្ម អត់មានទៅណាមកណាទៀតទេ ។

ដានីៈ អ៊ីចឹងលោកពូនៅខាងកំពង់ធំ នៅខាងជាមួយតាពីន នៅជាប់តាពីន រហូត?

អ៊ិនៈ បាទ!

ដានីៈ នៅខាងកំពង់ធំរហូតដល់ពេលណាទៅ?

អ៊ិនៈ ដល់យើងសមាហរណកម្ម ។

ដានីៈ មានផ្លាស់ប្តូរទៅណាទៀតអត់?

អ៊ិនៈ អត់ទេ ។

ដានីៈ កាលហ្នឹងចុះមកវិញមានជួបប្រពន្ធកូនអត់?

អ៊ិនៈ ដល់ពេលគេឲ្យឡើង ខ្ញុំមកជួបប្រពន្ធឆ្នាំប៉ែតប៉ុន្មានទេ ៨៧គេឲ្យឡើង ខ្ញុំឡើងមកចូលទៅប្រពន្ធ ជួបប្រពន្ធ ក៏ហៅប្រពន្ធមកឡើងភ្នំ ។

ដានីៈ ៨៧ឡើងភ្នំមួយសារទៀត?

អ៊ិនៈ ឡើង ខ្ញុំចូលទៅស្រុកជួយចូលយកប្រពន្ធ ។

ដានីៈ ដល់ពេលអ៊ីចឹងគាត់មកជាមួយ?

អ៊ិនៈ បាទ! មកជាមួយ យកមកនៅ ។ ឡើងហើយនៅបាន១ខែគេឲ្យចុះមកវិញ នៅដីខ្មែរ ផុតទុក្ខហើយមកនៅដីខ្មែរ ។

ដានីៈ ដល់ពេលយកប្រពន្ធមកឡើងទៅណាវិញ?

អ៊ិនៈ នៅកន្លែងដដែល ។

ដានីៈ នៅក-៧ហ្នឹង?

អ៊ិនៈ ទៅនៅបាន១ខែគេឲ្យចុះមកវិញ ។

ដានីៈ គេឲ្យចុះមកនៅណា?

អ៊ិនៈ មកនៅអូរជីក ។

ដានីៈ ៨៧យើងចុះមកម៉េចបាន យួនមិនទាន់ចេញផង ទាល់តែឆ្នាំ៨៩-៩០ ។

អ៊ិនៈ ចុះមក ។

ដានីៈ តាម៉ុក ធ្វើផ្លូវនៅ?

អ៊ិនៈ គាត់ឈូសឡានបើកមិនស្រួលជ្រុលចូលជ្រោះ តែយើងបើកទប់ៗតិច ។

ដានីៈ ពីព្រោះកាលហ្នឹងបើតាមខ្ញុំដឹងតាមពូ មីង ខាងអន្លង់វែង ទាល់តែចុងឆ្នាំ៨៩-៩០ ពេលដែលកងទ័ពវៃបានអន្លង់វែងហើយ បានតាម៉ុក គាត់ឈូសផ្លូវយើងលំៗ បានឲ្យប្រជាជនចុះមក ។

អ៊ិនៈ ហ្នឹងហើយឈូសលំៗយើងចុះ ចុះ៨៧ ។

ដានីៈ ចុះ៨៧ទេ?

អ៊ិនៈ បាទ! ចុះមកហើយសង្គ្រាមមិនទាន់ចប់ណា អត់មានចប់ទេ ចុះមកគេឲ្យមកនៅអូរជីក អត់ទាន់ចប់ទេ ចុះមកនៅហ្នឹង ។ ដល់ពេលយើងថាធូរធារហើយ បានគេឲ្យមកនៅនេះ ខាងទាហានខាងក្នុងវៃរត់ទៅវិញទៀត តែរត់អត់ឡើងទេ រត់ទៅនៅអូរធំ ។

ដានីៈ អូរធំនៅណា?

អ៊ិនៈ អូរធំនៅអូរជីក ។

ដានីៈ អូរជីកខាងផ្ទះតាម៉ុកនោះហ្នឹង?

អ៊ិនៈ អត់ដល់ទេ អូរជីកលើនេះ នោះផ្ទះតាម៉ុក តែយើងឆ្លងនេះ ។

ដានីៈ នោះគេហៅស្ពានអូរជីក?

អ៊ិនៈ ស្ពានអូរជីក អូរតែមួយ តែគេហៅអូរជីកលើ ក្រោម ។

ដានីៈ ខាងលើហ្នឹងភូមិអីគេ? ឥឡូវភូមិអីវិញ?

អ៊ិនៈ នៅក្នុងឃុំផ្អាវទេដឹង ឃុំផ្អាវហ្នឹងឯងផ្ទុំហ្នឹង ។

ដានីៈ ហើយម៉េចទៀតទៅអីចឹង?

អ៊ិនៈ ដល់រត់ពីហ្នឹងទៅ ទៅនៅហ្នឹង ដល់អីចឹងគេខាងក្នុងនេះបាញ់ ដល់បាញ់អីចឹងទៅក៏កើតខាងមេគេលើៗមិនត្រូវគ្នា ឈ្លោះប្រកែកគ្នាបែកជើងខ្លះរត់តាមតាម៉ុក ពួកខ្ញុំអត់រត់ទៅទេ ក្រាញនៅនេះឯង ទាហានខាងក្នុងទៅក៏យើងចូលនឹងគេទៅ ក៏បានមកនៅយើងសព្វថ្ងៃ ។

ដានីៈ លោកពូនៅក្នុងកងពល៨០២រហូត ឬមានផ្លាស់មក៨០១វិញ?

អ៊ិនៈ ដល់ក្រោយមកបានគេផ្លាស់មកនៅនេះវិញ មិនដឹងឆ្នាំប៉ែតប៉ុន្មានទេបានគេផ្តាច់ពីហ្នឹងមកនៅ៨០១នេះ មិនដឹងប៉ែតប៉ុន្មានកាលហ្នឹង ។

ដានីៈ លោកពូ៨៧យើងចុះភ្នំមកនៅអូរជីក ហើយ ។

អ៊ិនៈ ហ្នឹងឯង ចូល៩៣បានគេផ្លាស់អូរជីកមកនៅ៨០១នេះ ។

ដានីៈ ហ្នឹងដូរកងពល?

អ៊ិនៈ ដូរហើយចេញពី៨០២មកនៅ៨០១ ។

ដានីៈ ចេញពី៨០២ មកនៅ៨០១វិញ?

អ៊ិនៈ បាទ!

ដានី៖ មកវរសេនាធំលេខប៉ុន្មានដែរ?

អ៊ីន៖ នៅជាមួយគាត់ដែរ គាពីន ។

ដានី៖ ហ្នឹងវរសេនាធំលេខប៉ុន្មាន គាពីន ហ្នឹង?

អ៊ីន៖ វរសេនាធំលេខប៉ុន្មានទេ ។

ដានី៖ ខាងទួលពង្រកន្លែងហ្នឹងមន្ទីរកងពលតា០៥ ។

អ៊ីន៖ ហ្នឹងកន្លែងកងពលគេហើយ ។

ដានី៖ កន្លែងសែនសុខ កន្លែងរបស់តាស៊ុន?

អ៊ីន៖ នេះកន្លែងរបស់តាពីន បែកភូមិគ្នា នេះកន្លែងតាពីន ។

ដានី៖ តាពីន ឥឡូវគាត់ទៅនៅណា?

អ៊ីន៖ ទេ តាំងពីសមាហរណកម្មលឺថាទៅនៅខេត្តព្រះវិហារ ឥឡូវបាត់ពីខេត្តព្រះវិហារមិនដឹងទៅនៅណាទៀត ។

ដានី៖ អាហ្នឹងវរសេនាធំ៨៩?

អ៊ីន៖ ៨៩ ។ ភូមិនេះហៅភូមិ៨៩ ដល់ក្រោយមកទៀតយើងរៀបចំរដ្ឋអំណាចគ្រប់គ្រងស្រួលបួលត្រឹមត្រូវ គេដាក់ភូមិទួលប្រាសាទវិញ ។

ដានី៖ ប្រាសាទនៅកន្លែងណាវិញ?

អ៊ីន៖ នោះប្រាសាទ ខាងនោះដើមដូង មានដើមឈើធំមួយ ហៅទួលប្រាសាទរហូត ភាគច្រើនដឹង ៨៩ ។

ដានី៖ តែលោកពូមកនៅនេះឆ្នាំណាទៅ?

អ៊ីន៖ ៩៣ គេដកពីហ្នឹងមកនៅហ្នឹង ។

ដានី៖ អ៊ីចឹងទៅនៅអូរជីកបានប៉ុន្មានឆ្នាំ?

អ៊ីន៖ បាន២-៣ឆ្នាំ ។

ដានី៖ អ៊ីចឹងតាំងពីឆ្នាំ៨៧ លោកពូមិនដែលចុះទៅខាងកំពង់ធំវិញទៀតទេ?

អ៊ីន៖ អត់ទេ គេឲ្យនៅតាមព្រំដែន ។

ដានី៖ នៅតាមព្រំដែននៅណា?

អ៊ីន៖ នៅតាមព្រំដែនតាមនេះ គេឲ្យនៅធ្វើការហ្នឹងរហូត ទៅដាំក្បាន្ត ។

ដានី៖ ពីព្រំដែនជប់រុនទៅខាងដាំក្បាន្ត?

អ៊ីន៖ បាទ!

ដានី៖ ពីខាងដាំក្បាន្តទៅដល់អានសេះ?

អ៊ិនៈ បាទ! អានសេះ តែនៅទើត្រឹមហ្នឹង មួយក្រុមខ្ញុំ និងតាពីន គេរុនទៅដាក់អានសេះក្រុមហ្នឹង ទៅធ្វើការនៅហ្នឹងឯង ។

ដានីៈ គេឲ្យបញ្ជូនទៅដល់អានសេះ?

អ៊ិនៈ តែនៅក្នុងដីថៃ ។

ដានីៈ ក្នុងដីថៃ?

អ៊ិនៈ បាទ!

ដានីៈ ទៅនៅក្នុងដីថៃវិញ?

អ៊ិនៈ នៅក្នុងដីថៃ ។

ដានីៈ ម៉េចអីចឹង?

អ៊ិនៈ បើយើងដើរខាងក្នុងដើរម៉េចបាន បើទាហាន អីចឹងយើងដើរដីថៃ ។

ដានីៈ អានសេះហ្នឹងទាហាននៅ?

អ៊ិនៈ នៅ ភ្នំហ្នឹងគេនៅរហូត យើងដើរម៉េចបាន ។

ដានីៈ ចុះខាងប្រាសាទព្រះវិហារ?

អ៊ិនៈ ប្រាសាទព្រះវិហារ ហ្នឹងកំលាំងយើងនៅ កំលាំងខ្មែរក្រហមគេនៅ ។

ដានីៈ កំលាំងខ្មែរក្រហម ខាងពូដែរឬមិនមែនទេ?

អ៊ិនៈ បាទ!

ដានីៈ ខាងកងពលរបស់ពូ ឬកងពលផ្សេង?

អ៊ិនៈ អត់ទេ គេផ្សេងទេ ។

ដានីៈ កងពលណាវិញ?

អ៊ិនៈ អេ៎! កងពលហ្នឹងឯង កងពល៨០១ហ្នឹងឯង តែដល់អីចឹងគេចែកជាក្រុមតាមវរសេនាតូចៗ ធ្វើការតាមមុខសញ្ញា គេចែកជាក្រុមៗ ។

ដានីៈ ដល់ពេលលោកពូដើរធ្វើការប្រពន្ធនៅណា?

អ៊ិនៈ ប្រពន្ធនៅអូរធំ មីងៗនៅហ្នឹង ។

ដានីៈ សុទ្ធតែមីងៗ?

អ៊ិនៈ សុទ្ធតែមីងៗ ពូៗដើរធ្វើការ តែមានពូ២-៣នាក់ដែលចាស់ៗ នៅជាមួយមីងៗ អ្នកដែលមានកំលាំងគ្រាន់ដើរហ្នឹងគេយកទៅប្រើដើរធ្វើការងារ ។

ដានីៈ យ៉ាងម៉េចបានយើងបំបែកចេញពីកងពល៨០២មកនៅ៨០១វិញ? មូលហេតុអីដែរលោកពូថាឆ្នាំ៩៣គេផ្លាស់ពីអូរធំមកនៅនេះ?

អ៊ិនៈ ខ្ញុំដូចអត់ដឹងទេ ព្រោះគេខាងលើៗ គេហូតម៉េចគេខាងលើ គេមិនពេញចិត្តចេះចុះ ដកបងឯងខ្ញុំទៅជាមួយ ព្រោះខ្ញុំនៅជាមួយបងឯង មួយកង មួយក្រុមចេញមក មិនដឹងមូលហេតុអីគេ ។

ដានីៈ ដល់៨០២នៅខាងណាវិញ?

អ៊ិនៈ ៨០២នៅខាងត្រពាំងប្រាសាទ កន្លែងស្រុកត្រពាំងប្រាសាទ ៨០២ ។

ដានីៈ ដល់ពេលឆ្នាំ៩៣លោកពូមកនៅនេះ?

អ៊ិនៈ មកនេះ ។

ដានីៈ មកនៅនេះទាំងក្រុមក្រុមគ្រួសារមកដែរ?

អ៊ិនៈ មកទាំងអស់ ។

ដានីៈ ផ្ទះនេះធ្វើតាំងពីឆ្នាំ៩៣មក?

អ៊ិនៈ អត់ទេ ទើបតែធ្វើបាន២០០៥ ។

ដានីៈ ឆ្នាំ៩៣នៅណា?

អ៊ិនៈ ឆ្នាំ៩៣នៅនេះឯង ដល់នៅនេះមួយសារទាហានដេញរត់ទៅវិញទៀត ។

ដានីៈ ទាហានដេញឆ្នាំណាទៀត?

អ៊ិនៈ ទាហានដេញកាលនោះ៩៤ ។ ៩៤ដេញទៅនៅអូរជីកហ្នឹងឯង ដល់នៅអូរជីកហ្នឹងបាន១ឆ្នាំ-២ឆ្នាំមិនដឹង ដល់អីចឹងបែកបាក់គេខាងលើៗ ដល់បែកបាក់ខាងលើក៏បែកកំលាំងគ្នានៅចុះឡើងមកក៏កើតរដ្ឋប្រហារមួយសារហ្នឹង ខ្លះផ្តាច់ខ្លួនចូលខាងរដ្ឋាភិបាលទៅ ខ្លះពួកខ្ញុំអត់ទៅ នៅប្រពន្ធកូនក្រាញនៅហ្នឹងអត់ទៅទេ ។ ដល់ខាងហ្នឹងផ្តាច់ខ្លួនទៅគេនាំកំលាំងមកវៃពួកខ្ញុំក៏ចូលជាមួយគេមក ។

ដានីៈ លោកពូពេលហ្នឹងមានបានតួនាទីអីដែរ?

អ៊ិនៈ អត់មានធ្វើអីទេ មហាជនសាមញ្ញៗ ។

ដានីៈ តែមកធ្វើកងទ័ពពេលយើងឆ្នាំ៩៣យើងដើរធ្វើការហើយ លោកពូនៅអត់មានតួនាទីជាប្រធានអីទេ?

អ៊ិនៈ បានដាំបាយឲ្យគេហូប ដាំបាយរួចធ្វើការ មានមេក្រុមគេ មេក្រុមគេហៅយើងដើរធ្វើការ យើងដើរទៅ ។

ដានីៈ ដល់ពេលឆ្នាំ៩៤ ពេលដែលទាហានរដ្ឋាភិបាលវៃមកយើងទៅអូរធំ?

អ៊ិនៈ បាទ! រត់ទៅ ។

ដានីៈ រត់ទៅដល់ឆ្នាំណាបានត្រឡប់មកវិញ?

អ៊ិនៈ ដល់បានមកនៅនេះវិញ?

ដានីៈ បាទ!

អ៊ិនៈ ដែលយើងសមាហរណកម្មចរចារត្រូវរ៉ូវគ្នាបានមកនៅនេះវិញ មកនៅហ្នឹងនៅរហូតទល់ឥឡូវ

ដានីៈ ពេលដែលខាងក្រុមតាម៉ុក ខាងត្រពាំងប្រាសាទ ខាងអន្លង់វែងបែកបាក់គ្នា បែកជាបក្សពួក ចាប់ពីឆ្នាំណា?

អ៊ិនៈ កៅប៉ុន្មានទេ ៩៨ហ្នឹងដែលបែកបាក់គ្នា ៩៨-៩៩ ។

ដានីៈ ៩៩ យើងសមាហរណកម្មហើយ ។

អ៊ិនៈ បាទ!

ដានីៈ តែមុនបែកបាក់គ្នា?

អ៊ិនៈ ៩៨ហ្នឹងឯងដែលបែកបាក់គ្នា ។

ដានីៈ ដែលតាសុន សេន គេសម្លាប់? តាំង៩៧ម្ល៉េះ?

អ៊ិនៈ ដែលខ្ញុំមកនៅនេះ៩៨-៩៩ ។

ដានីៈ ចុះ៩៧នៅណា?

អ៊ិនៈ នៅកន្លែងនោះទេ ។

ដានីៈ ចុះគេប្រទូស្តប្រគ្រាស់មានតាសុន សេន គេសម្លាប់ តាម៉ុក, តាប៉ុល ពត កំលាំងគាត់វៃគ្នា កាលហ្នឹងលោកពូនៅខាងនោះនៅឡើយទេ?

អ៊ិនៈ នៅ នៅខាងហ្នឹងទេ ។

ដានីៈ លោកពូយ៉ាងម៉េចដែរ រឿងដែលបែកបាក់គ្នា វៃគ្នា ចាប់គ្នា?

អ៊ិនៈ អត់ដឹងទេខ្ញុំ អត់មានដឹងអីទេ គេខាងលើៗគេបែកបាក់គ្នា គេនាំទៅត្រង់ណាយើងទៅត្រង់ហ្នឹងតាមគេ ដល់ពេលគេបែកបាក់គ្នារឿងតាម៉ុក គេបញ្ជូនខ្ញុំទៅជប់គគីរ ។

ដានីៈ បញ្ជូនទៅជប់គគីរ?

អ៊ិនៈ បាទ!

ដានីៈ ម៉េចបានបញ្ជូនទៅជប់គគីរ?

អ៊ិនៈ ពួកខ្ញុំនៅកំលាំង៨០១ មេ៨០១គេចាប់ហើយ ដល់ពេលក្រោមៗគេដកចេញនៅតែមីងៗ ។

ដានីៈ កុំឲ្យនៅជិតខ្មាំងយើងប៉ះបោរ?

អ៊ិនៈ បាទ! ខ្មាំងអីចឹង គេខ្លាចយើងប៉ះបោរទៅ ហ្នឹងគេដកចេញ ។

ដានីៈ ដកចេញទៅជប់គគីរ?

អ៊ិនៈ បាទ!

ដានីៈ ជប់គគីរនៅណាទៅ?

អ៊ិនៈ ជប់គគីរនៅខាងនោះស្មាច់ទៀត ។

ដានីៈ ស្រុកអីគេ?

អ៊ិនៈ ជប់គគីរ-ថ្មដូន មិនដឹងស្រុកអីខ្ញុំអត់ស្គាល់ ។

ដានីៈ ជប់គគីរ-ថ្មដូន?

អ៊ិនៈ បាទ!

ដានីៈ ជិតៗគ្នា ជប់គគីរ-ថ្មដូន?

អ៊ិនៈ បាទ! ជិតគ្នាដែរ នៅហ្នឹងបានប៉ុន្មានទាំគ្នាឡប់មកវិញ មកខាងនេះគេត្រូវវ៉ៃគ្នាហ្នឹងឡប់មកវិញ ប្រពន្ធនៅហ្នឹងរហូត ។

ដានីៈ ខាងណាខុស ខាងណាត្រូវ គេថាខាងនោះគេថាខាងតាប៉ុល ពត ក្បត់ៗ ខាងនេះថាខាងតាម៉ុក ធ្វើរដ្ឋប្រហារ ។ បើតាមលោកពូយ៉ាងម៉េចដែរករណី២ហ្នឹង?

អ៊ិនៈ ខ្ញុំពិបាកនឹងថា មិនដឹងខាងណាខុស ខាងណាត្រូវ ខ្ញុំនៅពីក្រោមគេ គេខាងណាឈ្នះទៅខាងហ្នឹង ខាងណាចាញ់អត់ទៅតាម ។

ដានីៈ ពីព្រោះពេលដែលបន្ទាប់ពីតាសុន សេន ស្លាប់ទៅ ចាប់ផ្ដើមឈ្លោះគ្នា ក្រោយមកចាប់បានតាប៉ុល ពត ហើយក្រោយហៅតា០៥, ០៦ទៅទៀត មានការកាត់ទោស មានការសម្លាប់ ហើយចោទថាខាងកងពលភាគច្រើននៅខាងត្រពាំងប្រាសាទនេះចូលដៃ ចូលជើងជាមួយខាងតាប៉ុល ពត ។ ពូមានដឹងរឿងនេះដែរទេ?

អ៊ិនៈ ខ្ញុំអត់ដឹងរឿងទេ ព្រោះខ្ញុំគេរុញឲ្យនៅធ្វើការបែកពីភូមិ រឿងគេខាងលើលំបាកមិនឲ្យដឹងទេ យើងកំបិកកំប៉ុក បើលឺតែគ្នាយើងនិយាយ ដឹងសាច់រឿងគេយ៉ាងម៉េចយើងអត់ដឹងទេ ធម្មតាគេអ្នកធំៗ យើងជាព្រៃគេដែលមើលមុខ រឿងអីដែលគេប្រាប់យើង ។ គ្រាន់តែគេថាឯងទៅធ្វើការកន្លែងនេះ ទៅៗ ហ៎!ទៅធ្វើការកន្លែងនោះ ក៏ទៅៗ កិច្ចការផ្ទៃក្នុងយើងអត់ដឹង ។

ដានីៈ ដល់ពេលខាងមេៗមួយចំនួនទៅចូលជាមួយរដ្ឋាភិបាល?

អ៊ិនៈ ចូល ។

ដានីៈ ចូលហើយនាំកំលាំងមកវិញ?

អ៊ិនៈ នាំមកវិញ ។

ដានីៈ ពេលហ្នឹងលោកពូនៅហ្នឹងនៅឡើយ?

អ៊ិនៈ នៅនេះទេ អត់ទៅទេ ដល់ពេលខាងមេៗខ្ញុំគេចូលទៅក្នុង នៅកូនៗគេបញ្ជូនចេញ ។

ដានី: បញ្ជូនទៅណា?

អ៊ីន: បញ្ជូនទៅជប់គគីរនោះ ហើយមេៗណា មេដូចតាជុំ ចូលទៅក្នុង តាកែវ ចូលទៅក្នុង តាពីន ចូលទៅខាងក្នុង អស់ហើយមេ អ៊ីចឹងនៅតែកូនគេរុញចេញ ។

ដានី: ខ្មាចយើងទៅតាម?

អ៊ីន: ខ្មាចយើងប៉ះបោរម៉េចមាំ តាមគេតាមឯង គេបញ្ជូនចេញ ។

ដានី: ដល់ពេលបញ្ជូនចេញទៅ?

អ៊ីន: បានកំលាំងខាងក្នុងឡើងមកពួកខ្ញុំចូលមុនគេ ។

ដានី: ចូលទៅយើងទៅណា?

អ៊ីន: ចូលទៅក៏មកនៅហ្នឹងទាំងអស់គ្នា ។

ដានី: គេអត់បញ្ជូនទៅវិ?

អ៊ីន: ហ្នឹងចប់ហើយ ។

ដានី: គេបញ្ចប់ហើយ?

អ៊ីន: សមាហរណកម្មហើយចប់ហើយ បញ្ចូលជាមួយគ្នាហើយយើងចប់អត់មានទៅវិណាទេ ។

ដានី: ដល់ចូលមកវិញយ៉ាងម៉េចវិញទៅ គេរៀបចំអីយ៉ាងម៉េច?

អ៊ីន: គេរៀបចំ គេចងក្រងជាភូមិ អ្នកណាគ្រប់គ្រង គេរៀបចំឲ្យក្របខណ្ឌដឹកនាំ ជាក្រុម ជាមេភូមិ គ្រប់គ្រងកំលាំងយើង មើលរៀបចំមើលដីធ្លីធ្វើស្រែ ប្រជាជនធ្វើស្រែ ធ្វើចំការ ចិញ្ចឹម ដាំដុះ រៀបចំគ្រប់គ្រងទៅ ។

ដានី: ដំបូងពេលដែលយើងរៀបចំជាភូមិ មុនដំបូងហៅភូមិ៨៩, ភូមិ៨៦ ក្រោយមកពេលណា យើងដូរចេញជាទួលប្រាសាទ, សែនសុខ, ទួលពង្រវិញ?

អ៊ីន: ដល់ពេលគេរៀបចំជាភូមិក្នុងក្រិត្យទៅគេដាក់ភូមិឈ្មោះទួលប្រាសាទអ៊ីចឹងទៅ ពីមុនដែលអត់ទាន់មានចូលក្នុងក្រិត្យទេ គេថាភូមិនៅខាងក្រៅ គេដាក់៨៩៧ ។

ដានី: អ្នកដែលផ្តួចផ្តើមហៅឈ្មោះអ៊ីចឹង ពីណាគេអ្នកផ្តួចផ្តើមដំបូងៗឡើយ?

អ៊ីន: ប្រជាជននៅនេះទាំងអស់គ្នាហ្នឹង ដូចថាដាក់ត្រកូលឲ្យហៅអ៊ីចឹង ព្រោះយើងមានប្រាសាទ ហើយ យើងដាក់ជាភូមិទួលប្រាសាទទៅ ។

ដានី: យើងធ្វើហ្នឹងសំណើរឡើងទៅណា?

អ៊ីន: ឡើងទៅថ្នាក់ឃុំ ថ្នាក់ស្រុក ឃុំគេមកនិយាយប្រជុំទៅរៀបចំ ថាភូមិនេះដាក់ទួលប្រាសាទទៅ គេរៀបចំធ្វើរបាយការណ៍ឡើងទៅលើ ។

ដានី: ធ្វើរបាយការណ៍ទៅ គេហៅថាទួលប្រាសាទហ្នឹងតាំងពីឆ្នាំណាមក?

អ៊ិនៈ ទួលប្រាសាទហ្នឹងតាំងពីឆ្នាំ២០០០ ។

ដានីៈ តែតាពីន ចេញអស់?

អ៊ិនៈ តាំងពីសមាហរណកម្មមកក៏បែកបាក់គ្នា ។

ដានីៈ គាត់មានតួនាទីអីដែរ?

អ៊ិនៈ អត់មានទេ ដល់ពេលយើងខាងក្នុង ខាងក្រៅស្រុះស្រួលត្រូវរ៉ូវគ្នាហើយ បងឯងចង់ទៅនៅណាក៏ទៅ ខ្ញុំចង់ទៅនៅណាក៏ទៅស្រេចតែចិត្តទាំងអស់ គេអត់មានហាមឃាត់ថាទៅនៅនេះទៅនៅនោះ អត់ទេ អ្នកណាចង់ទៅណាទៅៗ អ្នកណាចង់នៅនេះក៏នៅ ប៉ុន្មាននាក់ក៏នៅទៅព្រោះយើងអត់មានភ័យព្រួយអីទៀតទេ ។ រកទីកន្លែងរស់នៅធ្វើម៉េចឲ្យបានស្រួលបួល រកស៊ីទៅ ។

ដានីៈ មេៗគាត់ចេញទៅអស់?

អ៊ិនៈ អស់ ភូមិនេះមុនដំបូងនៅប៉ុន្មាននាក់ មិនបាន២០គ្រួសារទេ ។

ដានីៈ ថ្នាក់វរសេនាធំទៅទាំងអស់?

អ៊ិនៈ បែកបាក់ទាំងអស់ហើយ គ្មានដឹងណាណីទេ ។

ដានីៈ ដូចតាពីន ប្រធាន, អនុប្រធាន សមាជិក ទៅអស់ហើយ?

អ៊ិនៈ ទៅអស់ហើយ បែកបាក់គ្នាអស់ហើយ ។

ដានីៈ តែលោកពូដល់ពេលសមាហរណកម្មហើយ យើងនៅក្នុងក្របខណ្ឌទាហានទៀត ឬលែងហើយ?

អ៊ិនៈ អត់មានទាហានទេ អីចឹងបានខ្ញុំអត់មានអីនឹងគេ គេនៅក្នុងក្របខណ្ឌទាហាន ដល់រដ្ឋខាងលើកាត់រំសាយគេមានប្រាក់ឧបត្ថម្ភ ខ្ញុំគ្មានអីទាំងអស់ ស្អាតចេស ខ្ញុំឈប់ដោយខ្លួនឯង ។

ដានីៈ ឈប់ខ្លួនឯង?

អ៊ិនៈ ឈប់ដោយខ្លួនឯងគ្មានអ្នកណាគេបង្ខំទេ ខ្ញុំថាចប់ពីសង្គ្រាមខ្ញុំឈប់ធ្វើហើយទាហាន ។

ដានីៈ តែលោកពូធ្វើជាមេភូមិហ្នឹងយើងជ្រើសរើសតាំងពីគេកកើតជាភូមិ?

អ៊ិនៈ បាទ!

ដានីៈ ម៉េចបានគេជ្រើសរើសលោកពូ?

អ៊ិនៈ មិនដឹងយ៉ាងម៉េចបើប្រជាជនទូទាំងភូមិគេសំរេចឲ្យធ្វើ ចេះតែធ្វើ ខ្ញុំសុំគេឈប់២ដងហើយគេថាបើមិនធ្វើឲ្យពីណាមកគ្រប់គ្រង ដល់អីចឹងគេឲ្យធ្វើ ដល់ក្រោយមកទៀតគេមិនអស់ចិត្តគេបោះឆ្នោតទៀត គេបោះឲ្យទៀតខ្ញុំចេះតែធ្វើរហូតមក ។

ដានី៖ តែតាមភូមិ តាមឃុំផ្សេងៗ ខ្លះដូចគាត់មានតួនាទី គេចាត់តាំងឲ្យគាត់ធ្វើប្រធានភូមិ ប្រធានឃុំ?

អ៊ីន៖ ដូចតាវ៉ា គាត់មានតួនាទីគាត់ ដល់ចប់សព្វគ្រប់គេរៀបចំឲ្យគាត់ធ្វើជាមេភូមិ បើខ្ញុំមានស្អី តែខ្ញុំសុំគេឈប់ពីទាហានខ្ញុំឈប់ដោយខ្លួនឯងតែម្តង អត់មានពីណាបង្ខំ អត់មានពីណាអូសទាញ គិតតែមកធ្វើស្រែ និងចិញ្ចឹម ដាំដុះតែប៉ុណ្ណឹង នៅរហូតទល់ចេះ ។

ដានី៖ លោកពូកាលពីជំនាន់លោកពូនៅក្មេងៗ កាលពីជំនាន់ឆ្នាំ៧៥ យើងមើលក្របី កាលហ្នឹងគេហៅស្រុកប្រាសាទសំបូរអីចឹងដែរ ឬអត់ទេ?

អ៊ីន៖ ទេ កាលជំនាន់ហ្នឹងខ្ញុំដឹង ចាស់ៗគាត់ថានៅស្រុកសន្ទុក ។

ដានី៖ កាលហ្នឹងអត់មានស្រុកប្រាសាទសំបូរទេ?

អ៊ីន៖ អត់មានទេ ដល់ក្រោយមកទៀត ខ្ញុំទើបមកនេះទេ បានគេហៅស្រុកប្រាសាទសំបូរៗនោះខ្ញុំធ្វើសំបុត្រកំណើតខ្ញុំដាក់ស្រុកប្រាសាទសំបូរទៅ ធ្វើអត្តសញ្ញាណបណ្ណខ្ញុំដាក់អីចឹងទៅ ពីដើមខ្ញុំដាក់តែស្រុកសន្ទុកៗរហូត ។

ដានី៖ កំណើតកើតជានៅស្រុកសន្ទុកទេ?

អ៊ីន៖ នៅហ្នឹង នៅស្រុកសន្ទុក ។

ដានី៖ ស្រុកប្រាសាទសំបូរនៅម្តុំណា ខ្ញុំអត់ច្បាស់?

អ៊ីន៖ ស្រុកប្រាសាទសំបូរយើងទៅ ។

ដានី៖ នៅជាប់ស្រុកអីខ្លះ?

អ៊ីន៖ ជាប់សាលាវិស័យ ស្រុកកំពង់ស្វាយ ។

ដានី៖ ផ្លូវយើងចេញពីកំពង់ធំ ទៅព្រះវិហារ?

អ៊ីន៖ បាទ! ហ្នឹងហើយ ។

ដានី៖ ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្កជាប់គ្នាអត់? ឬអត់មានទេស្រុកប្រាសាទបល្ល័ង្ក?

អ៊ីន៖ អត់មានទេ មានតែស្រុកកំពង់ស្វាយ មិនដឹងមានអត់ទេ ។

ដានី៖ ជាប់សណ្តាន់អត់?

អ៊ីន៖ ជាប់ ស្រុកប្រាសាទសំបូរជាប់សណ្តាន់ ជាប់កំពង់ស្វាយ ។

ដានី៖ ជាប់ស្រុកសន្ទុក?

អ៊ីន៖ អីចឹងប្រាសាទសំបូរវាំនៅកណ្តាល ។

ដានី៖ ហើយនឹងជាប់ខេត្តព្រះវិហារដែល?

អ៊ីន៖ ជាប់ខេត្តព្រះវិហារ ។

ដានី: ជាប់ស្រុករៀងដែលអត់?

អ៊ិន: ជាប់ស្រុករៀង ព្រោះរៀងវាទយទៅនោះ អីចឹងប្រាសាទសំបូរវាញ៉ាកមកនេះដែល ។

ដានី: អីចឹងក្នុងជំនាន់៣ឆ្នាំ នៅក្នុងស្រុកសន្ទុកទេនោះ?

អ៊ិន: ស្រុកសន្ទុកទេ ខ្ញុំលឺចាស់ៗនិយាយ ដល់ក្រោយមកបានដឹងថាប្រាសាទសំបូរ ខ្ញុំធ្វើសំបុត្រកំណើតដាក់អីចឹងទៅ ។

ដានី: កាលជំនាន់៣ឆ្នាំច្របូកច្របល់ដែលអត់ទេ នៅខាងហ្នឹង?

អ៊ិន: ច្របូកច្របល់តែរឿងធ្វើស្រែ ចំការ ។

ដានី: ដូចមានផ្លាស់ប្តូរអី ដូចថាខាងគណៈឃុំ គណៈស្រុក មានការផ្លាស់ប្តូរ ។ អ្នកចាស់ធ្វើអីចឹងក្រោយមកមានអ្នកថ្មីគេចូលមក ។

អ៊ិន: កាលនោះមិនសូវចាប់អារម្មណ៍ គេផ្លាស់ប្តូរតែគ្នាគេ យើងគិតតែពីធ្វើស្រែ អត់មានគិតអីចឹងផងកាលហ្នឹង ។

ដានី: កាលជំនាន់យើងបាយរួម?

អ៊ិន: បាទ! អ្នកណាធ្វើអីធ្វើទៅ ខាងលើគេដោះដូរម៉េចយើងអត់ដឹង លឺគេហៅឃុំ ។

ដានី: ពីណាគេគណៈឃុំកាលហ្នឹង?

អ៊ិន: មិនដឹងឈ្មោះអីទេ មិនមែននៅនឹងភូមិខ្ញុំទេ មិនដឹងឈ្មោះអីប្រធានឃុំគេ គេអ្នកនៅស្រុកឆ្ងាយ ។

ដានី: អ្នកមកពីខាងណាមក?

អ៊ិន: មិនដឹងមកពីណាទេ គេនៅឆ្ងាយគេមកគ្រប់គ្រងហ្នឹង បើភូមិគេរើសអ្នកភូមិ ប្រធានភូមិនៅហ្នឹង ។

ដានី: ចុះខាងស្រុក?

អ៊ិន: ស្រុកអត់ដឹងដែរ អត់ដែលឃើញមុខគេ មិនស្គាល់គេ ។

ដានី: កាលហ្នឹងក្នុងតំបន់ប៉ុន្មានទៅ? នៅខាងភូមិលោកពូហ្នឹង?

អ៊ិន: មិនដឹងតំបន់ម៉េចផង ។

ដានី: តំបន់កំពង់ធំអីចឹង?

អ៊ិន: ដឹងតែភូមិ, ឃុំ, ស្រុក, ខេត្ត ដល់តំបន់មិនដឹងតំបន់ម៉េច ។

ដានី: អត់ដែលលឺតំបន់ទេ? អត់ដែលលឺភូមិភាគទេ?

អ៊ិន: លឺតែមិនចាប់អារម្មណ៍ មិនយកចិត្តទុកដាក់ មិនមែនដូចឥឡូវយើងដឹងការងារធ្វើ យើងចេះតែស្រាវជ្រាវរក កាលមុនអត់ គ្រាន់តែរស់ហូបឆ្អែតធ្វើការងារតែប៉ុណ្ណឹង ។

ដានី: អត់លំបាកអី?

អ៊ិនៈ អត់មានលំបាកអី បើគេធ្វើអីចឹងហើយទៅតាមគេទៅ។

ដានី: កាលហ្នឹងមានប្រជាជនថ្មី ប្រជាជនមូលដ្ឋានអីដែលអត់?

អ៊ិនៈ ប្រជាជនមូលដ្ឋាននៅហ្នឹងតែម្តង។

ដានី: តែមានប្រជាជនថ្មីអីគេជម្លៀសទៅ?

អ៊ិនៈ អត់មានទេ។

ដានី: អត់មានជម្លៀសទៅ?

អ៊ិនៈ មានតែអ្នកស្រុក អ្នកភូមិនៅហ្នឹង។

ដានី: អត់មានអ្នកជម្លៀសទេ?

អ៊ិនៈ អត់ទេ មានតែអ្នកស្រុក អ្នកភូមិគេនៅហ្នឹង។

ដានី: លោកពូដូចថាយើងចាប់ផ្តើមពីសមាហរណកម្មហើយ យើងចាប់ផ្តើមយ៉ាងម៉េចទៅធ្វើផ្ទះ ធ្វើសំបែង ដីធ្លី បែងចែកយ៉ាងម៉េច?

អ៊ិនៈ កាលពីសមាហរណកម្មយើងអត់ទាន់ថា អ្នកនេះត្រូវមានប៉ុណ្ណេះហាត់ ប៉ុណ្ណោះហាត់អត់ទេ ហើយម្យ៉ាងពួកខ្ញុំនៅដំបូងគ្មានអ្នកចង់បានទេរឿងដីនោះ បើថាដីកន្លះហាត់ធ្វើប៉ុណ្ណឹងទៅ បើដីនៅក៏ហីទៅ គិតតែពីរឿងចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក។ ដល់ក្រោយមកគេចងក្រងជាឯកសារ ឃុំគេរៀបចំថាឥឡូវដីណាមានប៉ុន្មាន ដល់អីចឹងយើងចេះតែខំអញ្ចាប់អានេះនោះគេថាចាប់អានោះ។ តែព្រៃស្រុកនេះមិនមែនដូចព្រៃយើងខាងនោះទេ ព្រៃឬស្សីកើតទាំងអស់ ព្រៃឈ្លូសនៅមិនចង់កើត សុទ្ធតែព្រៃស្រែ ព្រៃវាល។

ដានី: វាស្រួលបោះតិចៗ?

អ៊ិនៈ អត់បាច់លំបាកកាស់ទេ ចេះតែភ្ជួរទៅ លើកភ្លឺកាត់ៗ ដើមឈើមួយដើមៗមើលទៅអីចឹងឯង

ដានី: ដល់ក្រោយមកយើងចាប់តាមកំលាំងយើងចាប់បានប៉ុន្មាន យកប៉ុណ្ណឹងទៅ?

អ៊ិនៈ បាទ! ខ្លះមាន២ហាត់ ៣ហាត់ ដល់ពេលក្រោយមកគេរៀបចំថាអ្នកណាមានដីប៉ុន្មានចេះចុះចេះតែខំប្រឹងទៅ បែកហួរហើយម្យ៉ាងក្នុងតំបន់មីនអត់សូវហ៊ានទេ ខ្លះមានដី៣ហាត់ធ្វើបាន១ហាត់ ឬមួយហាត់កន្លះ ឬ២ហាត់។ ហើយធ្វើចេះតែភ័យខ្លាច ព្រួយបារម្ភ ព្រោះកន្លងមកមានហែររហូតភូមិខ្ញុំ។

ដានី: មីន?

អ៊ិនៈ បាទ! ស្លាប់រហូត។

ដានី: យ៉ាងម៉េចហ្នឹង? យើងដោះអត់អស់ឬក៏យើង?

អ៊ិនៈ យើងអត់ទាន់មានរាវ រាវកាលនោះខាងបងប្អូនមករាវ កន្លែងណាអធិភាពជាងគេយើងឲ្យគាត់រាវ ដូចជាផ្លូវឲ្យគាត់រាវតែមួយផ្លូវហ្នឹងទេ តំបន់ស្រែខ្លះយើងដើរទៅមានការផ្ទុះ បន្ទុំឲ្យគាត់រាវ បានជួយរាវៗ ត្រង់ណាមិនសូវមានប៉ះក៏មិនសូវចាប់អារម្មណ៍ដែរ ដល់យូរៗក្រោយឆ្នាំទៅមួយ កាលនោះក្មេងៗទៅឃ្វាលគោវាឃើញគ្រាប់ គ្រាប់ហ្នឹងមិនសំណាំថាផ្ទុះផងទេ ដាច់ក្បាលអស់ហើយនៅសល់តែកន្ទុយ ហើយវាកាន់មក ចាស់ៗឃើញគ្នាច្រើនដែរតែមិនសូវចាប់អារម្មណ៍ ក្មួយខ្ញុំហ្នឹងឯងកាន់មក មិនដឹងម៉េចរបូតដៃធ្លាក់ទៅអស់៣នាក់ ក្មេងៗទើបអាយុ៨ឆ្នាំ ។

ដានីៈ តូចៗ!

អ៊ិនៈ បាទ!

ដានីៈ ទាល់តែប្រយ័ត្នប្រយែង យើងកុំមើលងាយគ្រាប់ហ្នឹង តែឃើញកុំឲ្យប៉ះពាល់ ព្រោះគ្រាប់យើងមើលមិនដឹងទេ ទាល់តែអ្នកបច្ចេកទេសគេមើលថាយ៉ាងម៉េចៗ?

អ៊ិនៈ គេប្រជុំចេះតែណែនាំអប់រំម៉ែឪ ក្មួយតូចៗឃ្វាលគោឲ្យឃើញកុំឲ្យប៉ះ ឃើញហើយឲ្យមកប្រាប់អ៊ំ ចេះណែនាំរហូត នៅតែមានការភ្លាំងភ្លាត់ ។

ដានីៈ រាល់ឆ្នាំអីចឹង ឬអត់ទេ?

អ៊ិនៈ ជួនកាល២ឆ្នាំ-៣ឆ្នាំម្តង ។

ដានីៈ មកដល់សព្វថ្ងៃនេះអត់មានបញ្ហាដីធ្លីអីទេ?

អ៊ិនៈ អត់មានអីទេ ដូចថាដីយើងធ្វើ ដីតំបន់យើងនេះមិនមែនដូចគេក្នុងណា គេក្នុងគេចង់បាន១គ្រួសារ១០-២០ហាត់ ហើយយើងនេះខ្លះបាន៣ហាត់ ខ្លះបាន៥ហាត់តាមសមាជិកគ្រួសារគេច្រើនតិច គេមានកំលាំងធ្វើក៏ធ្វើបាន ខ្លះគ្នាអត់កំលាំងធ្វើតិចៗ ។

ដានីៈ លោកពូតាំងពីយើងសមាហរណកម្មហើយ យើងប្រៀបធៀបយើងសមាហរណកម្មហើយហើយកាលយើងនៅតស៊ូ មុនសមាហរណកម្ម មានការខុសគ្នាយ៉ាងម៉េចទាក់ទងពីការរស់នៅទាក់ទងពីជីវភាព ទាក់ទងពីសេរីភាព វាខុសគ្នាយ៉ាងម៉េចដែរតាមបទពិសោធន៍លោកពូ?

អ៊ិនៈ ខុស មុនសមាហរណកម្មខុសៗ ខុសយ៉ាងម៉េច? ខុសត្រង់ណា វាអត់មានទីលំនៅពិតប្រាកដ ទីលំនៅដូចសត្វទន្សាយក្នុងព្រៃអីចឹង ទៅនៅនេះតិចទៅ កាលនោះនៅមានសង្គ្រាមដល់ពេលដឹងថាទាហានឡើងដល់នេះ ដល់នោះ រត់ទៅទៀត រត់ចុះរត់ឡើង ហ្នឹងមុនសមាហរណកម្មៗ តែក្រោយមកសមាហរណកម្មនេះយើងរស់នៅដោយស្រួល មិនភ័យ មិនលំបាកមិនព្រួយបារម្ភៗ ហើយជីវភាពមុនដំបូងវាលំបាកហើយ ធម្មតាយើងដំបូងមិនទាន់មានណាកាលនោះកាប់នឹងចប អត់មានក្របី គោ អត់ស្គាល់គោផងកាលនោះ កាប់នឹងចប ចេះតែ

លើកភ្លឺធ្វើបុកៗ មួយឆ្នាំរីកបន្តិចៗ យូរៗទៅដល់អ្នកក្នុងគេមកយើងទិញគោ ក៏បានភ្ជួរគោ ហែហូររហូតមកទល់ដល់បច្ចុប្បន្នឥឡូវប្រែប្រួលបានច្រើនណាស់ ហើយបងប្អូនខ្ញុំយើងមិនដុន ដាបអីទេ ឥឡូវគោយន្តចង់គ្រប់គ្រួសារ វាធូរធារ ដាំដំណាំ ដំឡូងក៏បាន សៀងក៏បាន ស្រូវក៏បាន ។

ដានី: ឥឡូវយើងដាំអីក៏បាន យើងធូរធារជាងមុន?

អ៊ិនៈ ធូរជាងមុន ធូរមែនទែន ធូរណាស់ព្រោះយើងរស់នៅដោយមានសិទ្ធិសេរីភាព ចង់ធ្វើអីក៏កើត ចង់ធ្វើអីក៏បាន តែយើងកុំប៉ះរឿងបញ្ហាពីច្បាប់ដូចគេហាមឃាត់ហើយយើងចេះបំពាន វាគ្មានរឿងអីឲ្យប៉ះពាល់ផងទេរាល់ថ្ងៃ ភ័យព្រួយតែរឿងដំណាំធ្វើឲ្យទាន់រដូវ ទាន់ពេលវេលា តែប៉ុណ្ណឹង ហើយចិញ្ចឹមថែទាំវា ។

ដានី: តែខ្ញុំជួបពូមីងច្រើន តែអ្នកខ្លះគាត់គិតដូចលោកពូអីចឹង តែអ្នកខ្លះគាត់គិតថាកាលពីមុន កាលពីជំនាន់តស៊ូនៅលើភ្នំយើងមានរបប យើងគិតតែពីតស៊ូហូបចុកយើងមិនព្រួយបារម្ភទេ យើងមានរបបគ្រប់គ្រាន់ត្រូវហូបចុក ។ ដល់ពេលយើងសមាហរណកម្មហើយគឺខ្លួនទីពឹងខ្លួន គឺយើងត្រូវប្រឹងប្រែងធ្វើ ជួនណាបាន ជួនណាមិនបាន ។ អ្នកខ្លះគាត់គិតថាកាលពីមុនស្រួលជាងឥឡូវ យោបល់ហ្នឹងយ៉ាងម៉េចដែរ បើតាមលោកពូ?

អ៊ិនៈ យោបល់ខ្ញុំ អត់មានស្រួលទេកាលពីមុនសមាហរណកម្ម ពីព្រោះយើងគ្មានអនាគតពិតប្រាកដទេ ព្រោះយើងរស់នៅវាអត់ទៀង គ្មានអនាគតកូនចៅ អនាគតខ្លួនយើងវាអត់មាន ដីស្រែត្រង់ណា ដំណាំដាំដុះដូងស្វាយអត់មានទាំងអស់ យើងរស់តាមតែគេឲ្យស៊ី ពេលគេឲ្យស៊ីឆ្អែតទៅ ពេលគេមិនឲ្យអនាគតយើងអត់ ។ បានថាវាខុសគ្នា ក្រោយសមាហរណកម្មបងប្អូនយើងឃើញធំទូលាយច្រើនណាស់ របស់របរប្រើប្រាស់ ខ្លះរហូតដល់មួយផ្ទះម៉ូតូ២-៣គ្រឿង គោយន្តមាន គោពេញក្រោល អីចឹងម៉េចដូចគ្នា អត់ដូចគ្នាទេ ។ យើងរស់តែតួមនុស្ស ហើយសំរាប់អនាគតកូនអត់មាន មានអី ។

ដានី: ប៉ុន្តែអានេះជាយោបល់ កាលពីមុនយើងរបប អីចឹងមនុស្សរស់នៅដូចៗគ្នា ដល់ពេលឥឡូវយើងសេរីមានសេរីភាពរកស៊ីប្រឹងប្រែងទៅតាមកំលាំង ទៅតាមអ្នកខ្លះប្រឹងប្រែងខ្លាំង អ្នកខ្លះល្មមទៅ អ្នកខ្លះមិនសូវប្រឹងប្រែង គាត់ទៅនេះ ទៅនោះ ។ ដល់ពេលអីចឹងជីវភាពខុសគ្នាកាលពីមុនដូចគ្នា ឥឡូវគេមានបាន អ្នកខ្លះមិនសូវ អន់ថយដែរ ដល់អីចឹងពួកគាត់មិនសូវជាសប្បាយចិត្ត អីចឹងមែនឬយ៉ាងម៉េចដែលលោកពូ?

អ៊ិនៈ អាហ្នឹងវាអីចឹងឯង ព្រោះសប្បាយចិត្តអីបើយើងអត់ខំប្រឹង ខំរក ខំធ្វើ អាងតែថាសុខស្រួលហើយសិទ្ធិសេរីភាពមានហើយ អត់ខំប្រឹងគិតគូរអំពីជីវភាពរស់នៅអនាគតកូនចៅខ្លួន

ឯង ហ្នឹងគ្រាន់តែរស់ប៉ុន្មានហូបប៉ុណ្ណឹង បើធ្វើស្រែគ្រាន់តែព្រួសហើយមិនទៅថែទាំវាដែលបានផល ដែលគេកើនគេខំប្រឹងណាស់ ព្រោះខ្លួនទីពឹងខ្លួនទាល់តែយើងខំប្រឹង ។ ឧទាហរណ៍ថាយើងចង់បានអី ហើយយើងគិតគូរអនាគតកូនយើង កូនយើងធំហើយ យើងទៅរកថវិកាណាសំរាប់រៀបចំកូនចៅ បើអីចឹងទាល់តែយើងខំ ខ្លះវាអត់ខំទេ អាងតែស្រួលហើយក៏ហីទៅ ធ្វើបានប៉ុន្មានហូបប៉ុណ្ណឹងទៅ ដល់ពេលយើងធ្វើបានអីចឹង មានប្រជាជនខ្លះវាមានដែរ អាងគេមានគេបាន អត់ដឹងថាគេមានគេបានហ្នឹងមកពីហេតុអីទេ ប្រជាជនខ្លះគិតដល់ ប្រជាជនខ្លះអត់គិតដល់ទេ គិតតែធម្មតាៗ ។

ដានី: ហើយមួយទៀតបញ្ហាដីធ្លី គាត់ច្រើនមួយចំនួន មិនមែននេះទេ មួយចំនួនគាត់និយាយពីបញ្ហាប៉ះពាល់ដីធ្លីគាត់រវាងក្រុមហ៊ុនផ្សេងៗ ធ្វើឲ្យគាត់បាត់បង់ដីធ្លី ។

អ៊ីនៈ អាហ្នឹងខាងខ្ញុំអត់មានទេ អត់មានទេរឿងប៉ះពាល់ រឿងក្រុមហ៊ុនអត់មានទេ លឺតែម្ខាងគេត្រពាំងប្រាសាទ មួយជួរខាងនេះអត់មានទេ គេខាងនោះទេ ។

ដានី: តែលោកពូមានយោបល់យ៉ាងម៉េចដែរ ទាក់ទងនឹងរឿងដីធ្លីហ្នឹង?

អ៊ីនៈ ខ្ញុំថាអ្នកដែលគេពាក់ព័ន្ធជាមួយក្រុមហ៊ុន ម្យ៉ាងខ្ញុំថាកាលនោះម្ចាស់ដីអាចជាលក់ឲ្យគេ ដល់ពេលក្រោយមកទៅជាទាមទារថាក្រុមហ៊ុនចេះតែលូកលាន់យកដី បើមិនលក់ឲ្យគេដែលគេហ៊ានយក អាហ្នឹងវាអីចឹងឯង ។ ដូចដីខាងខ្ញុំគេទិញអត់មានទាន់ថាក្រុមហ៊ុនណាមកធ្វើអីមួយអត់មានទេ ។

ដានី: នេះមានក្រុមហ៊ុនគេមកទិញដែរ?

អ៊ីនៈ ហ្នឹងមិនដឹងជាក្រុមហ៊ុន ឬមិនក្រុមហ៊ុនទេ គេទិញដីតាមផ្លូវ១០ម៉ែត្រ, ២០ម៉ែត្រ, ៣០ម៉ែត្រ អត់មានគំរោងធ្វើអីដាំអីធំដុំ ជារាប់ហាត់អត់មានទេ អីចឹងអត់មានប៉ះពាល់អីទេខាងខ្ញុំ ។

ដានី: មួយទៀតទាក់ទងរឿងគោរពប្រពៃណីវិញ ពេលដែលយើងតស៊ូ ពេលដែលយើងនៅក្នុងព្រៃលើភ្នំ យ៉ាងម៉េចដែលទាក់ទងនឹងបញ្ហាប្រពៃណី ទំនៀមទំលាប់ សាសនាដែលយើងជាខ្មែរមានបុណ្យទានអីផ្សេងៗ យើងគោរពអីផ្សេងៗ ទៅវត្ត មានលោកត្រូវធ្វើបុណ្យ ដល់ពេលយើងនៅតស៊ូយ៉ាងម៉េចដែរ? ហើយយើងសមាហរណកម្មហើយយ៉ាងម៉េចដែរ ខុសគ្នាយ៉ាងម៉េច?

អ៊ីនៈ កាលយើងមុនសមាហរណកម្មដែលយើងនៅ នៅក្នុងព្រៃគ្មានកាន់រឿងប្រពៃណីអីទេ ហ្នឹងមិនគិតគូររឿងបុណ្យទានអត់ទេ អត់មានទេ ដល់ពេលក្រោយសមាហរណកម្មប្រជាជនយើងទាំងអស់ ទាំងគេ ទាំងខ្ញុំ គ្រែកអរណាស់ដែលមានវត្តអារាម មានព្រះសង្ឃដែលរក្សាប្រពៃ

ណីខ្មែរយើង ហើយក៏សប្បាយចិត្តក្នុងការធ្វើបុណ្យធ្វើទាន ពេលធ្វើបុណ្យធ្វើទានម្នាក់ៗសប្បាយចិត្តទាំងអស់គ្នា ។

ដានី: អ៊ីចឹងដោយសារលោកពូមានការរវល់ដែរ អ៊ីចឹងខ្ញុំអរគុណលោកពូច្រើនដែលផ្តល់ឲ្យខ្ញុំសំណេះសំណាលជាមួយលោកពូទាក់ទងពីបទពិសោធន៍ជីវិតរបស់លោកពូ ខ្ញុំអរគុណលោកពូច្រើន ។

អ៊ិនៈ បាទ!

**ចប់**